00721140

E91/3

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 28 / 07 / 2011
ម៉ោង (Time/Heure): 14 : 08
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

## អង្គជំនុំជម្រះសាលាដំបូង

កាលបរិច្ឆេទ: ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០១១

ជូនចំពោះ: ក្រុមមេធាវីការពារក្ដី អៀង សារី និង ភាគីទាំងអស់នៃសំណុំរឿង ០០២

ពី: ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

ចម្លងជូន: លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

កម្មវត្ថុ: សេចក្ដីសម្រេចលើសំណើរបស់ អៀង សារី សុំឲ្យដាក់បញ្ចូលប្រព័ន្ធគ្រប់គ្រងសំណុំរឿងរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតនៅក្នុងសំណុំរឿង (លេខឯកសារ E91)

យោងសំណើរបស់ អៀង សារី សុំឲ្យដាក់បញ្ចូលប្រព័ន្ធគ្រប់គ្រងសំណុំរឿង (Case Map) ទៅក្នុងសំណុំរឿង (លេខឯកសារ E91)

ប្រព័ន្ធគ្រប់គ្រងសំណុំរឿង ០០២ របស់ ក.ស.ច.ស គឺសំដៅទៅដល់ប្រព័ន្ធទិន្នន័យអេឡិចត្រូនិកផ្ទៃក្នុងដែលត្រូវបានប្រើប្រាស់ដើម្បីគ្រប់គ្រង និងរៀបចំព័ត៌មានដែលមាននៅក្នុងសំណុំរឿង។ ប្រព័ន្ធនេះត្រូវបានបង្កើតឡើងដោយការប្រើប្រាស់កម្មវិធី software វិភាគសំណុំរឿង។ ដូច្នេះ ប្រព័ន្ធគ្រប់គ្រងសំណុំរឿងពុំបង្កើតបានជាផ្នែកមួយនៃសំណុំរឿង ដែលភាគីអាចពិនិត្យមើលបានដោយអនុលោមតាមវិធាន ៨៦ នៃវិធានផ្ទៃក្នុងឡើយ។

ខុសពីការលើកឡើងនៅក្នុងសំណើខាងលើ ក.ស.ច.ស ពុំបានប្រគល់សំណៅចម្លងណាមួយនៃប្រព័ន្ធគ្រប់គ្រងសំណុំរឿង ០០២ របស់ខ្លួន ជូនដល់អង្គជំនុំជម្រះសាលាដំបូងឡើយ។ អង្គជំនុំជម្រះសាលាដំបូងបានបង្កើតប្រព័ន្ធទិន្នន័យសំណុំរឿង ០០២ ដោយខ្លួនឯងដោយផ្អែកលើឯកសារដែលខ្លួនអាចពិនិត្យមើលបាននៅក្នុងសំណុំរឿង។ ពុំមានឧបសគ្គណាមួយរារាំងក្រុមមេធាវីការពារក្ដីនីមួយៗ មិនឲ្យបង្កើតប្រព័ន្ធទិន្នន័យសំណុំរឿង

សម្រាប់ប្រើប្រាស់ផ្ទៃក្នុងដោយខ្លួនឯងឡើយផ្អែកលើព័ត៌មាននេះ ប្រសិនបើខ្លួនពិតជាមានចេតនាចង់ធ្វើដូច្នោះ។

អនុស្សរណៈនេះគឺជាចម្លើយតបជាផ្លូវការរបស់អង្គជំនុំជម្រះទៅនឹងសំណើខាងលើ ដែលមានលេខឯកសារ E91។